Diploma Programme
Programme du diplôme
Programa del Diploma

# Khmer A: literature – Higher level – Paper 1
# Khmer A : littérature – Niveau supérieur – Épreuve 1
# Khmer A: literatura – Nivel superior – Prueba 1

Wednesday 10 May 2017 (afternoon)
Mercredi 10 mai 2017 (après-midi)
Miércoles 10 de mayo de 2017 (tarde)

2 hours / 2 heures / 2 horas

---

### Instructions to candidates

- Do not open this examination paper until instructed to do so.
- Write a literary commentary on one passage only.
- The maximum mark for this examination paper is **[20 marks]**.

### Instructions destinées aux candidats

- N’ouvrez pas cette épreuve avant d’y être autorisé(e).
- Rédigez un commentaire littéraire sur un seul des passages.
- Le nombre maximum de points pour cette épreuve d’examen est de **[20 points]**.

### Instrucciones para los alumnos

- No abra esta prueba hasta que se lo autoricen.
- Escriba un comentario literario sobre un solo pasaje.
- La puntuación máxima para esta prueba de examen es **[20 puntos]**.

2217 – 0565



© International Baccalaureate Organization 2017

International Baccalaureate
Baccalauréat International
Bachillerato Internacional

https://xtremepape.rs/

សូមអ្នកសរសេរអត្ថាធិប្បាយបែបអក្សរសិល្ប៍ទៅលើអត្ថបទ**មួយ** ក្នុងចំណោមអត្ថបទទាំងពីរខាងក្រោមនេះ៖

**1.**

យើងពុំបានឮសំលេងលោកស្នងការឆ្លើយតបទេ តែយើងសង្កេតឃើញមុខបុរសពិសេសជូនស្ងួត ជូនជ្រួញចិញ្ចើម ហើយអស់មួយសន្ទុះធំទើបតបវិញ ៖

-ខ្ញុំបានបង្កប់ខ្លួនអស់ជិតកន្លះយប់ហើយ តែពុំបានលទ្ធផលអ្វីសោះ នាំតែរងាអត់ប្រយោជន៍ ប៉ុន្តែមិនសូវធុញទ្រាន់ទេ ព្រោះជាករណីយកិច្ចរបស់ក្រុមយើង ដែលត្រូវតែបំពេញដោយខានមិនបាន ។ លោកបានផ្ដាំឱ្យខ្ញុំចាត់ការនោះតទៅទៀតមែនទេ ?

បុរសពិសេសញញឹមងក់ក្បាលតែម្នាក់ឯង ជាមួយបំពង់ទូរស័ព្ទរួចក៏ដាក់មកវិញ ហើយងាកទៅកាន់សហការីទាំងពីរដែលអង្គុយចាំស្ដាប់ក្បែរនោះ....... ៖

-បងព្រិល ! បងឯងត្រូវទៅភូមិនេសាទជាប្រញាប់ ដើម្បីឃ្លាំចាំមើលចលនាពួកវានោះ ហើយជាពិសេសបងឯងត្រូវប្រយ័ត្នបំផុតក្នុងពេលជិតភ្លឺហ្នា៎ !

បុរសឈ្មោះព្រិល មាឧមាំ ដែលជាភ្នាក់ងារសម្ងាត់ដ៏ក្លាហានប្រចាំស្នងការដ្ឋានក្រុង ក្រោកឈរឡើងយ៉ាងរហ័សហាក់ដូចពេញចិត្តចំពោះមុខការ ដែលបុរសពិសេសប្រគល់ឱ្យបំពេញនេះណាស់ ទើបគាត់សួរតប ៖

-ក្រៅពីនេះ តើមានរឿងអ្វីទៀតទេលោក ?

-មាន ! ទូកនេសាទដែលចតនៅទីនោះទាំងប៉ុន្មាន ត្រូវពិនិត្យមើលឱ្យមែនទែន ក្រែងវាលួចចេញទៅរួចដោយនាំទាំងរបស់ដែលយើងកំពុងតាមដាននេះ ទៅលាក់នៅកន្លែងផ្សេងទៀត មុខតែមានការលំបាកដល់ពួកយើងច្រើនទៀតមិនខាន ។

ព្រិលភ្នាក់ងារទីមួយឱនក្បាលដើរចេញទៅក្រៅយ៉ាងក្លាហាន ពុំមានរួញរាចំពោះរន្ទះតំណក់ភ្លៀង និងធាតុរងាបន្តិចឡើយ នេះហើយជាភស្តុតាងនៃអ្នកធ្វើការបំរើជាតិ ។ ព្រិលចេញផុតទៅ ទើបបុរសពិសេសងាកមកកាន់ជនទីពីរ ទៀត ៖

-ភីនឯងធ្លាប់ស្គាល់ម្ចាស់បារកូឡាបសដែរឬទេ ?

ភីនជាភ្នាក់ងារទីពីរ បង្ហុយផ្សែងបារីពីមាត់តបថា ៖

-បាទ ! ធ្លាប់ស្គាល់ដែរ តែពុំសូវជាជិតដិតប៉ុន្មានទេ ព្រោះខ្ញុំបាទមិនសូវចេញចូលបារនោះញឹកញាប់.......

បុរសពិសេសទាញរូបថតមួយសន្លឹក មកដាក់ពីមុខភ្នាក់ងារភីន ៖

-នេះជារូបប្ដីប្រពន្ធម្ចាស់បារនោះមែនទេភីន ?

សែហ្វភីនឈ្ងោកពិនិត្យរូបថតបន្តិច ទើបងើបក្បាលតបវិញ ៖

-បាទ ! ហ្នឹងហើយ..... តែប្រពន្ធដូចមិនមែនហ្នឹងទេលោក......

-ខ្ញុំបាទស៊ើបដឹងរួចហើយ រូបស្រីនេះជាប្រពន្ធដើមរបស់គាត់ដែលសព្វថ្ងៃបើកហាងលក់ទំនិញយ៉ាងធំមួយ នៅមហាវិថីព្រះបាទមុនីវង្សភ្នំពេញ ហើយស្រីម្នាក់ដែលមកធ្វើជាម្ចាស់បារជាមួយគាត់នេះជាប្រពន្ធចុងឬក៏ជាសាហាយរបស់គាត់ប៉ុណ្ណោះ ។ គាត់នោះឈ្មោះមុយជាអ្នកជំនួញមានឈ្មោះម្នាក់នៅក្នុងស្រុកខ្មែរ តែដល់ក្រោយមកត្រូវក្រសួងមានសមត្ថកិច្ចចាប់បាន ពីបទរត់គយអីវ៉ាន់ទៅបរទេសហើយក៏ត្រូវរាជការពិន័យជាច្រើន ។ តាំងពីពេលនោះមកក៏បាត់មុខពីភ្នំពេញតែម្ដង ស្រាប់តែឥឡូវក៏ឃើញគាត់ធ្វើជាថៅកែបារនៅឯណេះវិញ ហើយមានអ្នកឱ្យការខ្លះថា គាត់កំពុងរៀបចំផែនការរត់គយធំៗណាស់ ប៉ុន្តែមិនទាន់ច្បាស់ដូច្នេះយើងត្រូវប្រយ័ត្នលើរូបគាត់ហ្នឹងបន្តិច ព្រោះគាត់ហ្នឹងធ្លាប់មានរបួសរួចម្ដងហើយ ។

ភីនងើបសម្លឹងមុខបុរសពិសេសរួចតប ៖

-ខ្ញុំឮគេថា គាត់នេះមានកាណូតឈ្នួលរត់ពីក្រុងយើងនេះ ទៅកោះកុងដល់ទៅពីរឯណោះ តែខ្ញុំមិនបានជាចាប់ភ្លឹកចំពោះបញ្ហានេះ ។

-យើងត្រូវប្រយ័ត្នបន្តិច ចំពោះមនុស្សដែលមានស្នាមរួចហើយភីន ! តើកាណូតគាត់នោះលេខប៉ុន្មានខ្លះ ?

-ខ្ញុំមិនទាន់ស្គាល់ដែរ តែស្អែកនេះខ្ញុំនឹងជូនមកលោកឱ្យបានស្គាល់ភ្លាម....... ។

https://xtremepape.rs/

-ប៉ុន្តែភីនឯងត្រូវបំពេញបេសកកម្មធំមួយ ដែលគ្មានអ្នកណាក្រៅអាចធ្វើបាន ។

-សូមលោកចេញបញ្ជាមកចុះ ទោះបីជាធំប៉ុនភ្នំសុមេរុក៏ខ្ញុំមិនរុញរាដែរ ធ្វើជ្រូកហើយមិនរាទឹកក្តៅទេទាន......

បុរសពិសេសលើកដៃទះស្មាភ្នាក់ងារសំណប់មួយដៃ ហើយបន្លឺសំលេងឡើងថា ៖

-ត្រូវភីនឯង ធ្វើការទាក់ទងជាមួយប្រពន្ធចុងថៅកែបារនេះឱ្យបានក្នុងពេលឆាប់ៗ ទោះបីត្រូវកាន់នាទីអ្វីក៏ដោយ ជាសាហាយស្រីនោះក៏បាន ឬជាគូលីក្នុងបារនោះក៏បាន ហើយបើត្រូវការចំណាយប៉ុន្មានក៏តាមចិត្តចុះ រួចពីនោះមកបើកិច្ចការទាក់ទងបានសម្រេចហើយ ចចាំខ្ញុំប្រាប់ការធំជាក្រោយ ។

សៃហ្វភីនបើកភ្នែកធំៗ ៖

-ខ្ញុំមិនហ៊ានលួចប្រពន្ធគេទេលោក.......

-បើសិនកាលៈទេសៈបង្គាប់ហើយ ភិនឯងត្រូវតែហ៊ាន ព្រោះករណីយកិច្ចយើងវាធំជាងអ្វីទាំងអស់ ហើយបើការប៉ុណ្ណោះភីនឯងធ្វើមិនកើតដែរ ថ្ងៃក្រោយថ្ងៃមុខភីនឯងនឹងក្លាយទៅជាអន់បំផុតនៅក្នុងក្រសួងយើង ។

សៃហ្វភីនសញ្ជឹងគិតធ្វើភ្នែកម៉ក់ៗ ៖

-ខ្ញុំប្រថុយតាមលោកបញ្ជាម្តងចុះ ប៉ុន្តែត្រូវលោកទទួលឡើងរកាដែកជំនួសខ្ញុំផងបានទេទាន ?

បុរសពិសេសសើច ៖

-បាន ! ខ្ញុំព្រមឡើងជំនួស ប៉ុន្តែភីនឯងតោងដឹងថា នាងនោះមិនមែនជាប្រពន្ធពេញច្បាប់របស់ថៅកែមុយនោះទេណ៎ា !

-អត់ទោស នាងនោះឈ្មោះអីលោក ?

-នាងឈ្មោះថាវរី ល្អផ្តាច់គេក្នុងស្រុកយើងនេះ អ្នកណាក៏ចង់បាននាងធ្វើជាសាហាយដែរ ប៉ុន្តែវាគ្មានសំណាង ។ ប្រហែលជាសំណាងភីនឯងខ្ពស់ផុតគេហើយ ទើបវាសនាតម្រូវឱ្យភីនឯងទៅបំពេញកិច្ចការនេះ...... ហ៎ាៗ......

ភ្នាក់ងារសម្ងាត់ទាំងពីរសើច មើលមុខគ្នាកក្អៀកដូចទឹកធ្លាក់ពីមាត់ក្អម បន្ទរជាមួយស្នូរទឹកភ្លៀងដែលលាន់ប្រសៗ មកលើកញ្ចក់ទ្វារបង្អួច ។

មិត្ត សាខុន, *អាថ៍កំបាំងទូកលេខ១១* (1968)



https://xtremepape.rs/

**2.**

## ជីវិត

អ្វីទៅពាក្យថាជីវិតនោះ បងប្អូនស្រីប្រុសគង់មានឆ្ងល់
ជីវិតកើតឡើងទៅតាមផល តាមបច្ច័យផ្តល់កើតតាមយុគ។
ជីវិតប្រព្រឹត្តទៅរាល់ថ្ងៃ មនុស្សសត្វប្រុសស្រីចងចាំទុក
កើតមានជីវិតមិនមែនសុខ គឺជាជម្រុកសំបុកកម្ម។
ជីវិតប្រែថាការស៊ីចុក ហូបសោយគ្រប់មុខជាប្រចាំ
មានទាំងនំនែកប្រហុកម៉ាំ ផ្សំកាប់ចិញ្ច្រាំជាអាហារ។
អាហារនេះពិតជាលេខមួយ ជាគ្រឿងជំនួយជួយកាយា
សេពសោយគ្រប់ពេលគ្រប់វេលា ទ្រទ្រង់ជីវ៉ាអោយធំធាត់។
អាហារចែកជាបួនប្រការ កវឡឹង្ការាហារតាមមាត់
ជាអាហារដុំទំពាញាត់ បំពង់កមាត់ជាទីមួយ។
ទីពីរគឺជាផស្សាហារ តាមឥន្ទ្រីយាជាជំនួយ
អ្នកទទួលសោយមានប្រាំមួយ លើកជាម្តងមួយខតទៅ។
ខមួយតាមភ្នែកសោយរូបភាព តូចធំខ្ពស់ទាបធាត់សខ្មៅ
សម្រស់ល្អស្អាតមានជាតិជៅ ពេលភ្នែកមើលទៅកត់សំគាល់។
រូបភាពខ្លះក្លាយចេញជាបុណ្យ រូបភាពខ្លះកុនមិនមានផល
បង្កើតជាបាបអកុសល យកជាបន្ទាល់មិនបានទេ។
ព្រះពុទ្ធជាម្ចាស់លោកបានដល់ នូវឋានមង្គល់ពិតប្រពៃ
ព្រះអង្គជាម្ចាស់លោកទាំងបី ដោយព្រះបារមីជាអរហន្ត។
ត្រៃលោកទាំងបីគឺកាមលោក បើសិនរាប់បូកដប់មួយជាន់
ទីពីររូបលោកមិនមែនអន់ ដប់ប្រាំមួយជាន់ព្រហ្មមានរូប។
រាប់ទីបីគឺអរូបលោក ឋានខ្ពស់ក្នុងលោកព្រហ្មគ្មានរូប
បួនជាន់ទៅលើក្រអូបធូប ឋានព្រហ្មគ្មានរូបជាឋានមេ។
អារម្មណ៍ខ្ញុំហាក់បានទៅដល់ ទីឋានមានផលខ្ពស់ផុតគេ
ទស្សនាគ្រប់ឋានមិនទំនេរ រួចកត់សរសេរជាភស្តុតាង។
សូមជូនបញ្ជាក់បញ្ចប់ក្តី គ្រប់ឋានអ្វីៗលាតត្រដាង
មនុស្សគ្មានកុសលគ្មានផលសាង មើលមិនឃើញរាងភពនោះទេ។
មានតែអរហន្តអ្នកមានសីល គ្មានជាប់ខ្វួចខិលគ្មានកាមេ
សំរេចឈានដល់កំពូលគេ ជាប់ថ្នាក់ជាមេកំពូលធំ។
អាចមើលឃើញយល់អស់គ្រប់ឋាន និស្ស័យទ្រង់បានដល់បរម
ដឹកនាំសត្វលោកអោយខិតខំ សាងបុណ្យសន្សំទៅបរលោក។

ចាន់ ចំណាន, *បណ្តាំកវី ភាគ២* (1999)

https://xtremepape.rs/